UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

**អង្គការសហប្រជាជាតិ**
**ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា**

# ទិវាសិទ្ធិមនុស្សអន្តរជាតិ

១០ ធ្នូ ២០០៩

## សន្ទរកថាថ្លែងដោយលោក គ្រីស្តូហ្វ ប៉េស្ស៊ូ

តំណាងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

***

*"ផ្លូវឆ្ពោះទៅរកយុត្តិធម៌ គឺជាមាគ៌ាដ៏ប្រសើរបំផុតឆ្ពោះទៅរកសុខសន្តិភាព"*

ថ្ងៃនេះជាទិវាសិទ្ធិមនុស្ស។ វាគឺជាថ្ងៃឈប់សំរាកនៅកម្ពុជា។ វាគឺជាថ្ងៃមួយដែលយើងទាំងអស់គ្នាសប្បាយរីករាយ និងអបអរសាទរដល់មនុស្សជាតិរួមរបស់យើង ៖ មនុស្សជាតិរួមរបស់យើង គឺជាអ្វីដែលយើងមានទូទៅជាមនុស្ស ហើយថែមទាំងភាពខុសគ្នារបស់យើងក្នុងភាពជាមនុស្សដែរ។ ប្រធានបទសំរាប់ឆ្នាំនេះ គឺការអត់ឱនឲ្យគ្នា និងការលប់បំបាត់ការរើសអើង។ នេះជាឱកាសមួយ ដែលមិនត្រឹមតែ ដើម្បីធ្វើការបូកសរុប និងឆ្លុះបញ្ចាំងអំពីការអនុវត្តន៍ផ្ទាល់ខ្លួនរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាគោលនយោបាយ និងការអនុវត្តន៍ផ្សេងៗរបស់រាជរដ្ឋាភិបាល ដែលគួរតែធ្វើជាគំរូនៅក្នុងសង្គមអំពីរបៀបរៀបចំឥរិយាបទនៃការអត់ឱនឲ្យគ្នា។

ការរើសអើងនិង ការអត់ឱនឲ្យគ្នា ជារឿយៗគឺជាឫសគល់នៃការរំលោភបំពានគ្រប់ប្រភេទនៅទូទាំងពិភពលោក៖ សង្គ្រាម ភាពចលាចលក្នុងសង្គម វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គ្រោះទុរ្ភិក្ស ដែលជារឿយៗបណ្តាលមកពីការមិនអត់ឱនឲ្យគ្នាខាងនយោបាយ និងសាសនា ការប្រកួតប្រជែងខាងសេដ្ឋកិច្ច និងគោលនយោបាយអភិវឌ្ឍន៍ ដោយផាត់ចេញនូវសហគមន៍ទាំងមូល ហើយថែមទាំងគំរាមកំហែងដល់តុល្យភាពដ៏ផុយស្រួយនៃប្រព័ន្ធអេកូឡូស៊ីរបស់ផែនដី។ វាមិនមែនជាការចៃដន្យទេ ដែលលោកស្រីណាវី ភីឡៃ ឧត្តមស្នងការសិទ្ធិមនុស្សបានគូសបញ្ជាក់នាពេលថ្មីៗនេះថា "គោលដៅចម្បងរបស់យើង គឺជួយលើកស្ទួយសង្គមឲ្យប្រាស់ចាកពីការរើសអើង និងពិភពលោកមួយ ដែលមានការប្រព្រឹត្តដោយស្មើភាពគ្នាចំពោះមនុស្សគ្រប់រូប"។ នេះក៏ព្រោះតែ ផ្លូវឆ្ពោះទៅរកយុត្តិធម៌ គឺជាមាគ៌ាដ៏ប្រសើរបំផុតឆ្ពោះទៅរកសុខសន្តិភាព។

**និយមន័យ ៖**

រើសអើង មានន័យថា ញែក និងបែងចែកបុគ្គល ឬក្រុមមនុស្ស ឲ្យដាក់ពីគ្នានៅក្នុងសង្គមទាំងមូល និងប្រព្រឹត្តទៅលើពួកគេមិនគប្បី ដោយការរិតត្បិតសិទ្ធិរបស់ពួកគេ។ ការរើសអើង គឺជាឥរិយាបទក្នុងកំរិតបុគ្គល និងសង្គម និងនៃគោលនយោបាយ និងការអនុវត្តន៍កំរិតរដ្ឋាភិបាល។ នៅក្នុងករណីក្រោយនេះ ការរើសអើង ធ្វើឲ្យខូចដល់គោលការណ៍ស្មើភាពគ្នានៅចំពោះមុខច្បាប់ ដែលជាគ្រឹះនៃនីតិរដ្ឋ។ តាមធម្មតា ការរើសអើង នាំឲ្យមានភាពអយុត្តិធម៌ និងការប្រព្រឹត្តមិនស្មើភាពគ្នា។

**ឫសគល់នៃការរើសអើង ៖**

មនុស្សត្រូវបានគេរើសអើង ដោយហេតុផលជាច្រើន ដូចជា ៖ មកពីជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ឋានៈ ឬដើមកំណើតសង្គម ជោគវាសនា ឬទស្សននយោបាយ ពួកគេអាចត្រូវបានប្រព្រឹត្តមកលើខ្លួន ដោយភាពខុសគ្នា ក្នុងក្របខ័ណ្ឌនៃសិទ្ធិទទួលបានម្ហូបអាហារ ឬទឹក ការអប់រំ កិច្ចគាំពារសុខភាព ការងារ ឬការការពារតាមផ្លូវច្បាប់ ហើយរិតតែអាក្រក់ជាងនេះទៀតនោះគឺ ពួកគេអាចត្រូវបានសំលាប់ បាត់ខ្លួន ធ្វើទារុណកម្ម ឬចាប់ដាក់ពន្ធនាគារ។ ក្នុងសម័យខ្មែរក្រហម ការរើសអើស និងការមិនអត់ឱនឲ្យគ្នា គឺជាគោលនយោបាយមានលក្ខណជាស្ថាប័ន និងដែលបាននាំឲ្យមនុស្សរាប់សែននាក់ត្រូវស្លាប់។ ការមិនអត់ឱនឲ្យគ្នាខាងនយោបាយ និងជំលោះអន្តរជាតិ បាននាំឲ្យមានសង្គ្រាម និងការបំផ្លិចបំផ្លាញថែមទៀតនៅក្នុងទសវត្សទី៨០ និងមានឃាតកម្មជាច្រើនក្រោយឆ្នាំ១៩៩៣។

នៅពីក្រោយការរើសអើង វាទំនងជាមានឥរិយាបទរួមមួយ ៖ មនុស្សត្រូវបានគេប្រព្រឹត្តលើផ្សេងៗគ្នា ដោយសារតែពួកគេខុសគ្នា ឬទំនងជាខុសគ្នា។ ការពិតនៃឥរិយាបទនេះ ទំនងជាមកពី ៖ ប្រសិនជាពួកគេមិនដូចខ្ញុំ គឺពួកគេខុសពីខ្ញុំ ហើយប្រសិនជាពួកគេខុសពីខ្ញុំ ពួកគេមិនសូវមានលក្ខណជាមនុស្ស មានតំលៃតិចជាងខ្ញុំ។ ឥរិយាបទនេះ គឺជាឫសគល់នៃភាពមិនអត់ឱនឲ្យគ្នានៅគ្រប់ស្រទាប់នៃសង្គម ហើយនាំឲ្យមានអំពើហឹង្សាគ្រប់បែបយ៉ាង។

**ការបង្ហាញទិដ្ឋភាពសកលនៃការរើសអើង ៖**

យោងតាមធនាគារពិភពលោក ស្ត្រីធ្វើការពីរភាគបីនៃម៉ោងធ្វើការពិភពលោក និងផលិតស្បៀងស្មើនឹងពាក់កណ្តាល នៃស្បៀងអាហារពិភពលោក ប៉ុន្តែពួកគេ បានទទួលកម្រៃត្រឹមតែ១០ភាគរយ នៃប្រាក់ចំណូលពិភពលោក និងមានទ្រព្យសម្បត្តិតិចជាង១ភាគរយនៃទ្រព្យសម្បត្តិពិភពលោកប៉ុណ្ណោះ។ ៩៨ភាគរយនៃកុមារពិការ នៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ មិនបានចូលរៀន។ ជនជាតិដើមភាគតិច មានចំនួន៥ភាគរយនៃប្រជាជនពិភពលោក ស្មើនឹង១៥ភាគរយនៃប្រជាជនក្រីក្របំផុតលើពិភពលោក។ នេះគ្រាន់តែជាឧទាហរណ៍មួយចំនួនប៉ុណ្ណោះ។

ចូរយើងលើកឧទាហរណ៍ដែលនៅជិតយើងបំផុត ៖ ប្រសិនជាខ្ញុំចាត់ទុកកូនស្រីខ្ញុំមិនសូវសំខាន់ដូចកូនប្រុស ដោយសារតែនាងជាស្រីនោះ នោះខ្ញុំនឹងផ្តល់ឱកាសឲ្យនាងតិចជាងកូនប្រុស ក្នុងការសិក្សា ដើម្បីបង្កើនសមត្ថភាព និងកសាងជីវិតរបស់នាងជាងកូនប្រុស--សួរថាតើការធ្វើបែបនេះ យុត្តិធម៌ឬទេ ? តើកូនស្រីខ្ញុំ

មានប្រាជ្ញាវាងវៃ ឬសមត្ថភាពតិចជាងកូនប្រុសខ្ញុំឬយ៉ាងណា ? គឺមិនដូច្នោះទេ។ ដូច្នេះ ប្រសិនជាខ្ញុំប្រព្រឹត្ត ចំពោះនាងខុសគ្នាបែបនេះ  នោះខ្ញុំគឺជាអ្នកបំផ្លាញជីវិតរបស់នាងហើយ។

ប្រសិនបើខ្ញុំជានិយោជិក ហើយខ្ញុំបដិសេធមិនទទួលមនុស្សម្នាក់ ដែលមានសមត្ថភាព ឲ្យធ្វើការ ដោយសារតែគាត់ជាស្ត្រី ឬគាត់មានពណ៌សម្បុរខុសពីខ្ញុំ ឬគាត់ជាមនុស្សស្រលាញ់ភេទដូចគ្នា តើការធ្វើដូច នេះយុត្តិធម៌ទេ? ទោះជាគាត់មានសមត្ថភាពក្តី ក៏ខ្ញុំប្រើគាត់ខុសពីគេដែរ ដើម្បីផាត់គាត់ចេញ។ តើឥរិយាបទ បែបនេះ មិនប៉ះពាល់ដល់អារម្មណ៍ខាងក្នុងខ្លួនពីយុត្តិធម៌ទេឬ ?

ប្រសិនបើខ្ញុំជាចៅក្រមម្នាក់ ហើយត្រូវដោះស្រាយជំលោះដីធ្លីមួយ រវាងអ្នកក្រម្នាក់ និងអ្នកមាន អំណាច ហើយខ្ញុំកាត់សេចក្តីឲ្យអ្នកមានឈ្នះ ដោយសារតែគាត់ជាអ្នកមានអំណាច ថាតើការធ្វើបែបនេះ យុត្តិធម៌ទេ? ក្នុងនាមជាចៅក្រមមួយរូប ខ្ញុំមានមុខងារសំរេច ថាតើអ្នកណាជាម្ចាស់កម្មសិទ្ធិស្របច្បាប់លើដី មានទំនាស់នោះ ស្របតាមលក្ខណវិនិច្ឆ័យដែលច្បាប់បានកំណត់ ៖ លក្ខណវិនិច្ឆ័យ មិនបាននិយាយអំពី ទ្រព្យសម្បត្តិ ឬឋានៈរបស់ម្ចាស់កម្មសិទ្ធិឡើយ។ ប្រសិនជាខ្ញុំសំរេចសេចក្តីផ្អែកលើទ្រព្យសម្បត្តិ ឬឋានៈ របស់បុគ្គលនោះ នោះខ្ញុំមិនបានប្រព្រឹត្តចំពោះមនុស្សទាំងនេះដោយស្មើភាពគ្នានោះទេ ខ្ញុំមិនគោរពច្បាប់ ហើយខ្ញុំប្រព្រឹត្តចំពោះអ្នកក្រ ក្នុងភាពជាមនុស្សតិចជាង។ ប្រសិនបើក្នុងនាមជាចៅក្រម ហើយខ្ញុំប្រព្រឹត្ត បំពានច្បាប់  សួរថាតើអ្នកណា ជាអ្នកការពារយុត្តិធម៌ ?

## ការរើសអើង និងនីតិរដ្ឋ ៖

នៅក្នុងសង្គម ការអប់រំ និងនីតិរដ្ឋគឺជាឧបករណ៍ដែលប្រសើរបំផុត ក្នុងការប្រយុទ្ធប្រឆាំងនឹងការ រើសអើង និងការមិនអត់ឱនឲ្យគ្នា។

*តើច្បាប់អន្តរជាតិចែងអ្វីខ្លះ អំពីការរើសអើង ?* មាត្រា២៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ចែងថា "ជនគ្រប់រូប មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលបានការការពារពី ច្បាប់ស្មើគ្នា ដោយឥតរើសអើង"។

*តើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងអ្វីខ្លះ ?* (មាត្រា៣១) ចែងថា "ប្រជាពលរដ្ឋខ្មែរមានភាពស្មើ គ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌ សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈ សង្គម ធនធាន ឬ ស្ថានភាពឯទៀតឡើយ"។

នៅក្នុងប្រព័ន្ធនីតិរដ្ឋ ច្បាប់គឺជាអ្នកគ្រប់គ្រងសង្គម និងធ្វើនិយតកម្មលើរាល់ទំនាស់ ពីផលប្រយោជន៍ ក្នុងសង្គម។ នេះគឺជាលក្ខណខុសពីរបបផ្តាច់ការ ដែលបុគ្គលម្នាក់ ឬមនុស្សមួយក្រុមតូច ជាអ្នកប្រើប្រាស់ អំណាច។ ក្នុងប្រព័ន្ធនីតិរដ្ឋ ច្បាប់អនុវត្តចំពោះមនុស្សគ្រប់រូប ហើយគ្មាននរណាម្នាក់ ស្ថិតនៅពីលើច្បាប់ ឡើយ។ នេះគឺជាគោលការណ៍សមភាពចំពោះមុខច្បាប់។ ប្រសិនជាគោលការណ៍នេះ ត្រូវបានអនុវត្តក្នុង គោលនយោបាយ និងការអនុវត្តន៍ផ្សេងៗនោះ នោះការរើសអើងនឹងត្រូវបានបំបាត់បន្តិចម្តងៗ។ ការនេះនឹង ត្រូវប្រើពេលវេលា។ ការកសាងនីតិរដ្ឋ និងសង្គមមួយដែលមានការអត់ឱនឲ្យគ្នា គឺជាដំណើរការមួយដ៏វែង ដោយជួនកាលមានការរីកចំរើន ហើយជួនកាលមានការដើរថយក្រោយ។

**យើងសូមរំលឹកអំពីឧទាហរណ៍វិជ្ជមានមួយចំនួន ៖**

គោលនយោបាយលើកកំពស់ស្ត្រី នៅក្នុងសង្គម ៖ ស្ត្រីគឺជាឆ្អឹងខ្នងនៃសង្គមកម្ពុជា។ ពួកគេមិនគ្រាន់តែធ្វើការក្នុងគ្រប់វិស័យនោះទេ ប៉ុន្តែពួកគេថែមទាំងធ្វើការងារយ៉ាងច្រើនខាងសេដ្ឋកិច្ចគ្រួសារ ចិញ្ចឹម និងអប់រំកូនទៀតផង។ សកម្មភាពវិជ្ជមានមួយទៀត បានបញ្ចូលក្រុមសកម្មភាពបញ្ច្រៀបយេនឌ័រ ក្នុងក្រសួងចំនួន ២៥ ការកើនឡើងនៃចំនួនស្ត្រីជាប់ឆ្នោតក្នុងរដ្ឋសភា ការតែងតាំងស្ត្រីជាអភិបាលរងខេត្ត-ស្រុក នៅទូទាំងប្រទេស កូតាសំរាប់ការជ្រើសរើសស្ត្រីឲ្យបំរើការក្នុងមុខងារសាធារណៈ។ល។ គោលនយោបាយទាំងនេះត្រូវបានគាំទ្រពីថ្នាក់ដឹកនាំកំពូល ហើយបានទទួលលទ្ធផលជាបណ្តើរៗ។

សេរីភាពខាងសាសនា ត្រូវបានធានាការពារដោយរដ្ឋធម្មនុញ្ញ ហើយត្រូវបានគោរពក្នុងការអនុវត្តន៍ជាក់ស្តែង ៖ យើងមិនបានដឹងអំពីការរិតត្បិតធ្ងន់ធ្ងរណាមួយទៅលើសាសនាភាគតិចឡើយ។

សេរីភាពក្នុងការបង្កើតសមាគម ៖ ចាប់តាំងពីឆ្នាំ១៩៩៣មក កម្ពុជាបានបង្កើតរបបសេរីនិយមមួយ សំរាប់អង្គការក្រៅរដ្ឋាភិបាល ទាំងក្នុងស្រុក និងក្រៅស្រុក។ នេះគឺជាគំរូមួយនៃការអត់ឱនឲ្យគ្នាចំពោះប្រជាពលរដ្ឋក្នុងការរៀបចំខ្លួន ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍ជាតិ។ យើងសង្ឃឹមថា កម្ពុជានឹងរក្សាភាពជាអ្នកដឹកនាំរបស់ខ្លួនបន្តទៀតលើវិស័យនេះ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងបណ្តាឆ្នាំថ្មីៗនេះ អង្គការក្រៅរដ្ឋាភិបាលបានសំដែងពីទស្សនៈរិះគន់របស់ខ្លួន ចំពោះរដ្ឋាភិបាល ដែលចេះតែបានដាក់ការគាបសង្កត់មកលើខ្លួន។ យើងសង្ឃឹមថា រាជរដ្ឋាភិបាល និងសង្គមស៊ីវិល នឹងចូលរួមក្នុងកិច្ចសន្ទនាគ្នាដែលនឹងជួយពង្រឹងដល់ការអត់ឱនឲ្យគ្នា និងគោរពភាពចំរុះនៃគំនិត ជាពិសេសនៅពេលដែលច្បាប់អង្គការក្រៅរដ្ឋាភិបាលត្រូវបានអនុម័ត។ កិច្ចសន្ទនាបែបនេះ នឹងធានាដល់ការអាចយកច្បាប់នេះមកអនុវត្តបាន យោងតាមស្មារតីនៃរដ្ឋធម្មនុញ្ញ នៅពេលដែលច្បាប់នេះ នឹងត្រូវបានអនុម័ត ហើយវាមិនក្លាយជាច្បាប់មួយ សំរាប់ដាក់ការគាបសង្កត់លើអង្គការក្រៅរដ្ឋាភិបាលឡើយ។ ការិយាល័យយើងខ្ញុំ នឹងបន្តធ្វើការជាមួយរាជរដ្ឋាភិបាល សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីបង្កបរិយាកាសមួយឲ្យច្បាប់នេះអាចអនុវត្តបាន។

ការលើកកំពស់សិទ្ធិជនពិការ គឺជាវិស័យមួយទៀតនៃការរីកចំរើនកន្លងមក ដោយមានការគាំទ្រពីអាជ្ញាធរជាន់ខ្ពស់បំផុត។ ច្បាប់មួយក្នុងវិស័យនេះត្រូវបានអនុម័តនៅឆ្នាំនេះ និងមានការផ្តល់ជំនួយសង្គមកិច្ចមួយចំនួន ដល់គ្រួសារយុទ្ធជនដែលពិការដោយសារសង្គ្រាម និងគ្រាប់មីន។

ការអប់រំ ៖ ស្ថិតិបង្ហាញថាកុមារី និងស្ត្រីបានរងផលប៉ះពាល់ធ្ងន់ធ្ងរក្នុងវិស័យសិក្សាធិការដែលបណ្តាលឲ្យអត្រាអនក្ខរភាពរបស់ស្ត្រីមានកំរិតខ្ពស់ជាងបុរស។ នៅក្នុងអំឡុងពេលដប់ឆ្នាំកន្លងមកនេះ ក្រសួងអប់រំបានទទួលជោគជ័យក្នុងការធានាឲ្យមានភាពស្មើគ្នា នៃសិស្សចូលសិក្សានៅសាលារៀនតាមកំរិតបឋមសិក្សា នេះគឺជាសមិទ្ធផលមួយដ៏សំខាន់។ ការខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីឲ្យឈានដល់កំរិតដូចគ្នានេះនៅកំរិតមធ្យមសិក្សា ហើយការនេះ ទំនងជាត្រូវប្រើពេលដប់ឆ្នាំទៅមុខទៀត ដើម្បីអាចសំរេចកិច្ចការនេះបាន។ ប៉ុន្តែ ទាំងនេះគឺជាកិច្ចខិតខំប្រឹងប្រែងជាវិជ្ជមាន ដើម្បីកាត់បន្ថយការរើសអើងរវាងបុរសនិងស្ត្រី ៖ ដោយចាប់ផ្តើមចេញពីកុមារី និងកុមារាទៅ។

ក្នុងករណីនេះ ដោយរួមគ្នាជាមួយអង្គការយូណេស្កូ និងអង្គការយូនីសេហ្វ ការិយាល័យយើងខ្ញុំបាន និងកំពុងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើតកម្មវិធីអប់រំសិទ្ធិមនុស្ស ដែលសំដៅដល់ការអប់រំពលរដ្ឋវិជ្ជា តាមសាលារៀន ដើម្បីអប់រំក្មេងជំនាន់ក្រោយរបស់មនុស្សជាតិ និងប្រជាជន អំពីសញ្ញាណធម្មតាតែសំខាន់នៃការរស់នៅជាមួយគ្នា ៖ ការគោរពចំពោះអាយុជីវិត និងសេរីភាព ការគោរពភាពផ្សេងគ្នានិងភាពចំរុះ ការគោរពខ្លួនឯងនិងអ្នកដទៃ ការគោរពផែនដីដែលឲ្យកំណើតយើង និងជួយឲ្យយើងមានជីវិតរស់នៅ។ យើងបានសង្កេតឃើញនិន្នាការគួរឲ្យព្រួយបារម្ភនៅក្នុងបណ្តាឆ្នាំថ្មីៗនេះ។

នៅខេត្តរតនគីរី ជនជាតិភាគតិច បាននិងកំពុងរស់នៅអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយនៅលើដីធ្លីរបស់ខ្លួន ប៉ុន្តែនៅប៉ុន្មានឆ្នាំថ្មីៗនេះ ដោយសារដីធ្លីបានក្លាយជាប្រភពថ្មីមួយនៃទ្រព្យសម្បត្តិនោះ ទើបពួកគាត់ត្រូវបានគេដកហូតសិទ្ធិលើដីធ្លីរបស់ខ្លួន។ ច្បាប់ភូមិបាល គួរការពារសិទ្ធិពួកគាត់លើដីធ្លីរបស់ពួកគាត់ផង ប៉ុន្តែនៅក្នុងករណីភាគច្រើន ច្បាប់នេះមិនត្រូវបានយកមកអនុវត្តឡើយ ហើយពីមួយថ្ងៃទៅមួយថ្ងៃ អ្នកមានផលប្រយោជន៍សេដ្ឋកិច្ចដ៏មានអំណាចបានប្លន់យកដីធ្លីរបស់អ្នកភូមិ ដែលជារឿយៗមានការគាំទ្រពីអាជ្ញាធរ។ ហេតុអ្វីបានកើតមានបញ្ហានេះ? ពីព្រោះពួកគេមិនមែនជាជនជាតិខ្មែរ ពួកគេត្រូវបានចាត់ថាជាអ្នកគ្មានអារ្យធម៌ ពួកគេជាអ្នកក្រ មិនចេះនិយាយភាសាខ្មែរ មានរបៀបរបបរស់នៅខុសប្លែកពីគេ និងជាជនទន់ខ្សោយ  ហើយដែលងាយនឹងរងគ្រោះ។

សហគមន៍ក្រក្រីជាច្រើននៅភ្នំពេញ ត្រូវបានចាត់ទុកថាជា "អ្នកតាំងលំនៅខុសច្បាប់" "អ្នកតាំងលំនៅមិនរៀបរយ" "ពួកអនាធិបតេយ្យ" នៅពេលដែលពួកគេមួយចំនួនធំ មានសិទ្ធិកម្មសិទ្ធិស្របច្បាប់លើដីនោះ ដែលគេរស់នៅតាមច្បាប់ភូមិបាល។ ដោយប្រកាសពួកគេថា"ខុសច្បាប់" ធ្វើឲ្យមានការមិនយកចិត្តទុកដាក់ថែមទៀតដល់សិទ្ធិរបស់ពួកគេតាមច្បាប់។ នេះគឺជាការប្រព្រឹត្តមួយ ដែលមានការរើសអើង ដែលនាំឲ្យមានវិវាទ និងការបណ្តេញចេញ។ ប្រសិនបើអនុវត្តច្បាប់ភូមិបាលបានត្រឹមត្រូវ  វិវាទដីធ្លីជាច្រើន នឹងមិនកើតឡើងទេ ហើយអាចដោះស្រាយបាន។ ជាការពិតណាស់ មានពួកឱកាសនិយមដែលឆ្លៀតកេងប្រយោជន៍ពីវិវាទដីធ្លី ដើម្បីទទួលបានសំណងមិនត្រឹមត្រូវ  ក៏ប៉ុន្តែពួកទាំងនេះ មិនមានចំនួនច្រើនទេ។ មានតែការអនុវត្តន៍ច្បាប់ភូមិបាលឲ្យបានត្រឹមត្រូវទេ ទើបអាចបែងចែកនរណាមានសិទ្ធិស្របច្បាប់ និងនរណាខ្លះមិនមានសិទ្ធិលើដីធ្លីរបស់ពួកគេ។ សំរាប់គោលបំណងនេះ  ច្បាប់ត្រូវយកមកអនុវត្តឲ្យបានស្មើភាពគ្នា។

រឿងក្តីលោកជំទាវមូ សុខហួរ ៖ តុលាការបានសំរេចបដិសេធបណ្តឹងស្តីពីបទបរិហារកេរ្តិ៍របស់លោកជំទាវ ហើយទទួលយកបណ្តឹងរបស់សម្តេចនាយករដ្ឋមន្ត្រី។ តើនេះគឺជាសេចក្តីសំរេចមួយត្រឹមត្រូវ ឬក៏មានការរើសអើង?

សេរីភាពនៃការបញ្ចេញមតិ ត្រូវបានធានាការពារក្នុងរដ្ឋធម្មនុញ្ញ  ហើយការអនុវត្តន៍សិទ្ធិនេះ ត្រូវធ្វើដោយសេរី តែក្នុងក្របខ័ណ្ឌកំណត់មួយចំនួន ៖ ដូចជាមិនត្រូវរិះគន់ជាសាធារណៈនូវគោលនយោបាយរបស់រាជរដ្ឋាភិ បាល  ការអនុវត្តន៍ជាក់ស្តែង ឬឯកត្តបុគ្គលទាំងឡាយ លើបញ្ហាជាក់លាក់ណាមួយ--ជាពិសេសបើការរិះ គន់ទាំងឡាយណាដែលមើលឃើញថា ចេញមកពីសំលេងនយោបាយប្រឆាំង។ កាលពីប៉ុន្មានខែថ្មីៗនេះ យើងសង្កេតឃើញពីការធ្វើព្រហ្មទណ្ឌនីយកម្ម នៃការបញ្ចេញមតិមួយចំនួន ៖  បុគ្គលមួយចំនួនបានសំដែង នូវទស្សនរបស់ខ្លួនពីបញ្ហាពុករលួយនៃមន្ត្រីជាន់ខ្ពស់មួយចំនួន ការដាក់ភ្លើងបំភ្លឺនៅអង្គរវត្ត ឬការអភិរក្ស ត្រីផ្សោតនៅតាមទន្លេមេគង្គជាដើម។ ទាំងអស់នេះ គឺជាការបញ្ចេញមតិ ហើយមិនមែនជាបទ

ល្មើសទេ-ទោះបីជានៅពេលខ្លះ គំនិតទាំងនេះចេញមកពីសំលេងប្រឆាំងក៏ដោយ។ រដ្ឋធម្មនុញ្ញបង្កើតរបបនយោបាយ ពហុនិយម។ ភាពខុសគ្នាខាងគំនិត ក្នុងបរិយាកាសនយោបាយយោគយល់គ្នាមួយ មិនគួរដោះស្រាយតាម រយៈការគំរាមកំហែង ការបំភិតបំភ័យ ឬបណ្តឹងព្រហ្មទណ្ឌនោះទេ តែតាមរយៈការជជែកពិភាក្សាទល់មុខគ្នាជាសាធារណៈ។ មធ្យោបាយដែលល្អបំផុតដើម្បីតបតចំពោះការកុហក ឬមតិដែលមិនមានព័ត៌មានគ្រប់ គ្រាន់ ព័ត៌មានក្លែង គឺត្រូវតបតដោយការផ្តល់ព័ត៌មានអង្គហេតុ និងការពិត តាមរយៈការពិភាក្សា។ គំនិត ផ្សេងៗគ្នាក្នុងសារព័ត៌មាន អាចដោះស្រាយបាន តាមរយៈសិទ្ធិឆ្លើយតប ៖ ការឆ្លើយតបត្រូវចុះផ្សាយនៅក្នុង សារព័ត៌មាននោះឆ្លើយតបចំពោះការចោទប្រកាន់ដោយផ្តល់ហេតុពិត និងទឡ្ហីករណ៍។ សច្ចៈភាពគឺជាអាវុធ ដែលល្អបំផុតប្រឆាំងតបនឹងការកុហស និងការក្លែងបន្លំ។ ដាក់នរណាម្នាក់ក្នុងពន្ធនាគារដោយសារតែគាត់ បញ្ចេញទស្សនៈដោយសន្តិវិធី ទោះបីជាទស្សនៈនោះ ត្រូវបានបញ្ចេញសំរាប់ហេតុផលនយោបាយក៏ដោយ គឺជាអាកប្បកិរិយាមួយនៃភាពមិនយោគយល់ខាងនយោបាយ ៖ គឺវាផ្ទុយនឹងគោលការណ៍នីតិរដ្ឋ និងបំពានស្មារតីរដ្ឋធម្មនុញ្ញ។ នីតិរដ្ឋ គឺមិនគ្រាន់តែជានីតិរដ្ឋនោះទេ ពីព្រោះច្បាប់អាចមានការកៀបសង្កត់ និងមិន យុត្តិធម៌។ នីតិរដ្ឋពិតប្រាកដ គឺផ្អែកលើគោលការណ៍សមភាពចំពោះមុខច្បាប់ និងយុត្តិធម៌។ បើគ្មានគោល ការណ៍ទាំងនេះទេ នីតិរដ្ឋ អាចក្លាយជាប្រហោងក្នុង និងស្ថិតតែលើបបូរមាត់ប៉ុណ្ណោះ។

ជាសេចក្តីសន្និដ្ឋាន ខ្ញុំសូមបន្ថែមថា ការប្រយុទ្ធប្រឆាំងនឹងការមិនយោគយល់គ្នា គឺជាការទទួលខុសត្រូវរបស់យើងទាំងអស់គ្នា នៅគ្រប់ពេលទាំងអស់ ៖ ទោះក្នុងនាមជាឯកត្តបុគ្គលក្នុងជីវភាពប្រចាំថ្ងៃ ដោយផ្អែកលើការយល់ដឹង របស់យើងពីតំរូវការទទួលយក និងតំលៃខុសៗគ្នាជាប្រភពធនធាន និងមិនមែនជាការគំរាមកំហែង ទោះ ក្នុងនាមជាមាតាបីតាចំពោះកូន ទោះក្នុងនាមជាគ្រូបង្រៀនតាមរយៈប្រព័ន្ធអប់រំ តាមរយៈសិទ្ធិមនុស្ស ឬការអប់រំពលរដ្ឋវិជ្ជា ទោះក្នុងនាមជាតួអង្គសង្គមស៊ីវិល ទោះក្នុងនាមជាសិល្បករ និងតួសំដែងវប្បធម៌ ហើយ ចុងក្រោយបំផុតនោះ ទោះក្នុងនាមជាអ្នកនយោបាយ និងអ្នកដឹកនាំ ដើម្បីធ្វើជាគំរូដល់សង្គមមិនត្រឹមតែជាពាក្យសំដីទេ តែតាមរយៈអំពើ ឬសកម្មភាពផងដែរ។ ទាំងនេះ គ្រាន់តែជាការឆ្លុះបញ្ចាំងមួយចំនួនដែលខ្ញុំចង់ចែករំលែកជាមួយលោក-អ្នក នៅថ្ងៃនេះ ដើម្បីជួយដល់ការពិភាក្សាលើប្រធានបទដ៏លំបាកតែមាន សារសំខាន់នេះ។

សូមអរគុណ។